# អវសានបទ

គោលនយោបាយសំរាប់អភិវឌ្ឍកម្មវិធីសិក្សាចំនេះទូទៅជាឯកសារគោលមានតំលៃក្នុងការប្រើប្រាស់តាមការចាំបាច់ និងតំរូវការនានានៃគ្រប់អង្គភាពជំនាញដែលពាក់ព័ន្ធនៅក្រោមឱវាទក្រសួងអប់រំ យុវជន និង កីឡា និងគ្រប់អង្គការជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល អង្គការសហគមន៍ទាំងអស់ដែលកំពុងមានបេសកកម្មជួយគាំទ្រវិស័យអប់រំ នៅកម្ពុជា។

ក្រសួងអប់រំ យុវជន និង កីឡាសូមអោយគ្រប់អង្គភាពជំនាញដែលពាក់ព័ន្ធខិតខំអនុវត្តគោលនយោបាយនេះអោយមានប្រសិទ្ធភាពដោយឈរលើមូលដ្ឋាននៃខ្លឹមសារដែលបានចែងក្នុងផ្នែកនីមួយៗនៃឯកសារស្របទៅតាមភារកិច្ចនិងជំនាញរបស់អង្គភាពនីមួយៗនោះ ។

ក្រសួងអប់រំ យុវជន និង កីឡាសង្ឃឹមថា អង្គការជាតិ និងអន្តរជាតិនានានឹងបន្តចូលរួមលើកកំពស់គុណភាពអប់រំនៅកម្ពុជាអោយកាន់តែល្អប្រសើរឡើងប្រកបដោយជោគជ័យ។ នេះជាការចូលរួមចំនែកដ៏ធំបំផុតក្នុងការអនុវត្ត គោលនយោបាយអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។

ក្រសួងអប់រំ យុវជន និង កីឡាប្រកាសអោយប្រើប្រាស់ជាផ្លូវការនូវគោលនយោបាយសំរាប់អភិវឌ្ឍកម្មវិធីសិក្សាចំនេះទូទៅឆ្នាំ ២០០៥-២០០៩ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០៤

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**